# សេចក្តីថ្លែងការណ៍ទាំងស្រុងរបស់សមាគមសហព័ន្ធខ្មែរចិននៅកម្ពុជា

(ការបកប្រែក្រៅផ្លូវការ)

កាលពីថ្មីៗនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្រៅប្រទេសបានបន្តពន្លើស និងរាយការណ៍អំពីការឆបោកតាមប្រព័ន្ធអ៊ីនធឺណេតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសការធ្វើការវិភាគ និងបកស្រាយដោយគ្មានមូលដ្ឋានអំពីឧក្រិដ្ឋកម្មឆបោកនៅកម្ពុជា និងបង្កើតរូបភាពបំផ្លើសមកលើប្រទេសកម្ពុជាថាជា "ជម្រកឧក្រិដ្ឋកម្ម" របស់ក្រុមសម្ព័ន្ធឧក្រិដ្ឋកម្ម ដែលទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងពីជុំវិញពិភពលោក។

តើពិតជាមានករណីបែបនេះដែរទេ? ក្នុងរយៈពេលជាង២០ឆ្នាំមកនេះ ប្រទេសកម្ពុជាមានសុខសន្តិភាព និងស្ថិរភាព សណ្តាប់ធ្នាប់សង្គមមានភាពល្អប្រសើរ ប្រជាពលរដ្ឋបានរស់នៅ និងប្រកបការងារដោយសុខសន្តិភាព ឧស្សាហកម្មផ្សេងៗមានការរីកចំរើន ហើយប្រទេសនេះបានក្លាយជាចំនុចដ៏ទាក់ទាញនៃការវិនិយោគពីបរទេស។ មុនពេលការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ-១៩ សេដ្ឋកិច្ចជាតិបានរក្សាបាននូវអត្រាកំណើនប្រចាំឆ្នាំជាមធ្យមប្រហែល ៧ភាគរយ ដែលជាសេដ្ឋកិច្ចរីកលូតលាស់លឿនបំផុតមួយនៅក្នុងតំបន់។ បន្ទាប់ពីមានការរាតត្បាតនៃជំងឺនេះ រាជរដ្ឋាភិបាលដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាត់វិធានការទប់ស្កាត់ និងគ្រប់គ្រងយ៉ាងរហ័ស និងមានប្រសិទ្ធភាព ដែលធ្វើឱ្យប្រទេសកម្ពុជាឈ្នះលើការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះយ៉ាងលឿន ហើយក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងគេក្នុងការបន្តដំណើរការសកម្មភាពសេដ្ឋកិច្ច និងសង្គមឡើងវិញ។.

ជាការពិតណាស់ វាជារឿងដែលមិនអាចប្រកែកបាន ដែលថាក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហ និងសេរីបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ ដែលធ្វើអោយប្រទេសកម្ពុជាទាក់ទាញការវិនិយោគពីបរទេសយ៉ាងច្រើន ដូចនេះវាជៀសមិនរួចទេ ក្នុងករណីខ្លះដែលយើងទទួលបានបុគ្គលនិងការវិនិយោគក្លែងក្លាយ។ ជាឧទាហរណ៍ បុគ្គលឈ្មោះ She Zhi Jiang ដែលជាមេដឹកនាំក្រុមឧក្រិដ្ឋជនឆបោក ទើបតែត្រូវបានចាប់ខ្លួនក្នុងប្រទេសថៃ ទៅលើការជាប់ពាក់ព័ន្ធក្នុងការឆបោកតាមអ៊ីនធឺណិត និងសកម្មភាពឧក្រិដ្ឋកម្មនៅប្រទេសកម្ពុជា ប៉ុន្តែវាមិនបានតំណាងឱ្យសេដ្ឋកិច្ចកម្ពុជាទាំងមូល ហើយក៏មិនមានន័យថាសកម្មភាពសេដ្ឋកិច្ចរបស់ជនជាតិខ្មែរ ឬជនបរទេសនៅកម្ពុជាគឺពឹងផ្អែកទៅលើរឿងទាំងនោះដែរ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអនុវត្តច្បាប់ក្នុងតំបន់ និងប្រទេសដែលពាក់ព័ន្ធ ដើម្បីបង្ក្រាបរាល់សកម្មភាពឧក្រិដ្ឋកម្មឆ្លងដែន និងកំពុងខិតខំលុបបំបាត់ "ដំបៅមហារីក" ដែលធ្វើឲ្យខូចមុខមាត់ប្រទេសយ៉ាងធ្ងន់ធ្ងរ។

សមាគមសហព័ន្ធខ្មែរចិននៅកម្ពុជា សហការយ៉ាងសកម្មទៅលើសកម្មភាពអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល និងខិតខំប្រឹងប្រែងដោយខ្លួនឯង ដើម្បីរក្សាមុខមាត់ដ៏ល្អនៃអន្តរជាតិរបស់កម្ពុជា និងកែលម្អបរិយាកាសទូទៅនៃធុរកិច្ច។ ខាងក្រោមនេះ គឺជាអ្វីយើងសូមធ្វើការអំពាវនាវដល់មិត្តក្នុងប្រទេស និងក្រៅប្រទេសដែលមានដូចជា៖

1. **សូមប្រយ័ត្នចំពោះអន្ទាក់នៃ "ការប្រកាសជ្រើសរើសបុគ្គលិក "ប្រាក់ខែខ្ពស់" ហើយត្រូវយល់ពីខ្លឹមសារ និងលក្ខខ័ណ្ឌនៃការងារ។ ក្នុងករណីមានអាសន្នក្នុងប្រទេសកម្ពុជា សូមជូនដំណឹងដល់នគរបាលមូលដ្ឋាន ឬទាក់ទងស្ថានទូត និងស្ថានកុងស៊ុលនៅកម្ពុជាឱ្យបានទាន់ពេលវេលា ដើម្បីសហការយ៉ាងសកម្មជាមួយនគរបាលក្នុងការប្រយុទ្ធប្រឆាំងនឹងសកម្មភាពឧក្រិដ្ឋកម្ម។**
2. **មិត្តអ្នកសារព័ត៌មាន សូមរាយការណ៍ពីការពិតនៃប្រទេសកម្ពុជាដោយមិនលំអៀង និងត្រឹមត្រូវ។ ជៀសវាងការប្រឌិតនូវចំណាប់អារម្មណ៍ក្លែងក្លាយ និងបំផ្លាញមុខមាត់ប្រទេសកម្ពុជា។**
3. **សូមកុំបំផ្លើស និងបកស្រាយដោយគ្មានមូលដ្ឋានថាជា «ឧក្រិដ្ឋកម្មឆបោក» និងសកម្មភាពពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា ជាពិសេសការបំភ្លៃពីសារៈសំខាន់នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវរបស់ប្រទេសចិនថាជាចេតនាទុច្ចរិត។ គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ បាននាំមកនូវផលប្រយោជន៍យ៉ាងធំធេងដល់ប្រទេសកម្ពុជា និងប្រទេសដទៃទៀតទៅតាមមាគ៌ារបស់វា។ យើងគាំទ្រយ៉ាងមុតមាំក្នុងការលើកកម្ពស់គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ ដើម្បីសម្រេចបាននូវការផ្សារភ្ជាប់គ្នា និងរួមចំណែកដល់ភាពរុងរឿង និងការអភិវឌ្ឍន៍ក្នុងតំបន់។**

សមាគមសហព័ន្ធខ្មែរចិននៅកម្ពុជា មានឆន្ទៈចែករំលែកពីមុខមាត់ពិតនៃបរិយាកាសធុរកិច្ចរបស់កម្ពុជាជាមួយមិត្តក្នុងប្រទេស និងក្រៅប្រទេសដើម្បីផ្តល់ជំនួយចាំបាច់សម្រាប់មនុស្សគ្រប់គ្នាក្នុងការធ្វើការរស់នៅ និងវិនិយោគនៅកម្ពុជា!

និមិត្តសញ្ញាសមាគម

**ដោយក្តីគោរពពីសមាគមសហព័ន្ធខ្មែរចិននៅកម្ពុជា**

**ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២**

Unofficial Translation